# ដំណឹងជ្រើសរើសបុគ្គលិក

## ឆ្មប (០១ រូប)

## គ្លីនិកម៉ារីស្តូប សៀមរាប (ទីរួមខេត្ត)

អង្គការម៉ារីស្តូបអន្តរជាតិកម្ពុជា គឺជាអង្គការអន្តរជាតិមួយដែលផ្តល់សេវាថែទាំសុខភាពបន្តពូជ, ពន្យារកំណើត និងសេវារំលូតប្រកបដោយសុវត្ថិភាពដល់ស្ត្រី។ សេវាកម្មដែលយើងផ្តល់ជូន ផ្តល់ឱ្យស្ត្រីនូវសិទ្ធិក្នុងការជ្រើសរើសនៅពេលដែលគាត់មានគ៌ភ ដើម្បីឱ្យគាត់មានសេរីភាពក្នុងការបន្តផែនការ និងសម្រេចក្តីសុបិន្តរបស់គាត់ និងគ្រួសារគាត់។ ចក្ខុវិស័យរបស់យើងគឺ **ពិភពលោកមួយដែលគ្រប់កំណើតទាំងអស់សុទ្ធតែជាការចង់បាន** ហើយបេសកកម្មរបស់យើងគឺដើម្បីធានានូវសិទ្ធិរបស់បុគ្គលៈ **មានកូនតាមប្រាថ្នាមិនមែនតាមការចៃដន្យ**។ អង្គការម៉ារីស្តូបអន្តរជាតិកម្ពុជាត្រូវការជ្រើសរើសបុគ្គលិកឆ្មប សម្រាប់បំពេញមុខតំណែងដូចខាងក្រោមៈ

| ភារកិច្ចចំបង និងការទទួលខុសត្រូវ | លក្ខណៈសម្បត្តិរបស់បេក្ខជន |
|---|---|
| • ស្វាគមន៍គ្រប់អតិថិជនដែលអញ្ជើញមកគ្លីនិកដោយរួសរាយនិងមិនរើសអើង។<br>• ផ្តល់សេវាជូនអតិថិជនប្រកបដោយគុណភាពខ្ពស់ មានវិជ្ជាជីវៈ ស្របទៅតាមគោលការណ៍វេជ្ជសាស្ត្ររបស់ម៉ារីស្តូប។<br>• ធ្វើរោគវិនិច្ឆ័យនិងផ្តល់ការព្យាបាលជូនអតិថិជនឲ្យបានត្រឹមត្រូវ ក្នុងករណីដែលមិនច្បាស់ត្រូវស្វែងរកជំនួយពីប្រធានគ្លីនិក។<br>• ផ្សព្វផ្សាយអំពីសេវារបស់ម៉ារីស្តូបជូនអតិថិជនតាមរយៈការផ្តល់ប្រឹក្សាយោបល់យ៉ាងពេញលេញដល់គាត់។<br>• បំពេញព័ត៌មានរបស់អតិថិជននិងលិខិតព្រមព្រៀងទទួលសេវារបស់អតិថិជនមុនផ្តល់សេវា។<br>• ទំនាក់ទំនងទៅកាន់អតិថិជនដើម្បីតាមដានសុខភាពក្រោយរំលូត និងការប្រើប្រាស់មធ្យោបាយពន្យាកំណើត។<br>• រក្សាឯកសារ និងព័ត៌មានរបស់អតិថិជនអោយបានល្អ សម្ងាត់ និងមានសុវត្ថិភាព។<br>• ធានាថាបន្ទប់ផ្តល់សេវាស្អាត ឧបករណ៍ប្រើប្រាស់រៀបចំយ៉ាងមានសណ្តាប់ធ្នាប់ សម្ភារវេជ្ជសាស្ត្រត្រូវបានសម្អាតនិងសម្លាប់មេរោគយ៉ាងត្រឹមត្រូវ ។<br>• សហការជាមួយប្រធានគ្លីនិកក្នុងការគ្រប់គ្រងការប្រើប្រាស់ថ្នាំ<br>• ចូលរួមប្រជុំពិនិត្យនិងវិភាគលទ្ធផលការងារ និងបង្កើតសកម្មភាពផ្សេងៗដើម្បីបង្កើនប្រាក់ចំណូល អតិថិជន និងផលិតភាពការងារក្នុងគ្លីនិក។<br>• អនុវត្តភារកិច្ចផ្សេងៗទៀតទៅតាមការចាត់តាំងរបស់ប្រធានគ្លីនិក។ | • មានបទពិសោធន៍យ៉ាងតិច ២ ឆ្នាំ ឬ កម្រិតវប្បធម៌ត្រឹមឆ្មបមធ្យម ឬបរិញ្ញាប័ត្រឆ្មប។<br>• ទទួលបានការបណ្តុះបណ្តាលទាក់ទងនឹងការថែទាំក្រោយរំលូត បញ្ហាសុខភាពបន្តពូជ សុខភាពផ្លូវភេទ និងផែនការគ្រួសារ។<br>• រួសរាយរាក់ទាក់ក្នុងការទទួលភ្ញៀវ<br>• អាចធ្វើការងារជាក្រុមបានល្អ<br>• អត្តចរិកល្អ និងមានភាពស្មោះត្រង់<br>• មានភាពអំណត់ និងមានឆន្ទះក្នុងការរៀនសូត្របន្ថែម |

**អង្គការម៉ារីស្តូបកម្ពុជាផ្តល់ជូននូវ ប្រាក់បៀវត្សដែលមានលក្ខណៈប្រកួតប្រជែង និងអត្ថប្រយោជន៍ផ្សេងៗជាច្រើន ដូចជាប្រាក់ឧបត្ថម្ភក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ ធានារ៉ាប់រង២៤ម៉ោងលើសុខភាព(សម្រាប់បុគ្គលិកនិងគ្រួសារបុគ្គលិក) និងធានារ៉ាប់រងគ្រោះថ្នាក់ការងារ ការតម្លើងប្រាក់បៀវត្សប្រចាំឆ្នាំ ប្រាក់រង្វាន់លើកទឹកចិត្ត ប្រាក់សន្សំ និងអត្ថប្រយោជន៍ផ្សេងៗជាច្រើនទៀតតាមគោលការណ៍របស់អង្គការ។**

- ➢ បេក្ខជនបេក្ខនារីដែលមានចំណាប់អារម្មណ៍ចង់បម្រើការងារ សូមធ្វើប្រវត្តិរូបសង្ខេបដែលមានភ្ជាប់ជាមួយអត្តសញ្ញាណប័ណ្ណ ឬសៀវភៅគ្រួសារថតចម្លង និងរូបថត ៤ គុណ ៦ មួយសន្លឹក ផ្ញើមកកាន់អង្គការម៉ារីស្តូបអន្តរជាតិកម្ពុជា ដែលមានអាសយដ្ឋាននៅមជ្ឈមណ្ឌលភ្នំពេញ អគារ F ជាន់ទី១ ឬនៅតាមគ្លីនិកម៉ារីស្តូបដែលនៅជិតលោកអ្នក។
- ➢ លេខទូរស័ព្ទទំនាក់ទំនង ០២៣ ៩៩៤ ០៨៣ / ០៩៦ ៦៤០ ៨១១៨ ។ អ៊ីមែល hrd@mariestopes.org.kh ។
- ➢ ឈប់ទទួលពាក្យ **ថ្ងៃទី ១៥ ខែតុលា ឆ្នាំ២០២០**